វេទិកាវិមជ្ឈការ DECENTRALIZATIONFORUM

# ក្រុមការងារវេទិកា  វិមជ្ឈការ

## ជីវប្រវត្តិ

នៅឆ្នាំ២០០៣ បន្ទាប់ពី រៀបចំសិក្ខាសាលាមួយស្ដីពីភាពជាដៃគូដែលឧបត្ថម្ភដោយអង្គការស៊ីដសេ ក្រុមការងារភាពជាដៃគូ នៅក្នុងវិមជ្ឈការ (WGPD) បានកំណត់តម្រូវការទីតាំងជាក់លាក់មួយសម្រាប់អោយអ្នកពាក់ពន្ធ័សំខាន់ៗ មកពីវិស័យនានាអាច មកជួបជុំគ្នាពិភាក្សា ស្វែងរក បញ្ហាក្នុងការអនុវត្តន៍ និងដែលមានផលប៉ះពាល់ដល់ដំណើរការវិមជ្ឈការនៅកម្ពុជា។ ក្រុមការងារស្នើឱ្យ មានការរៀបចំវេទិកាវិមជ្ឈការជាប្រចាំ និងបង្កើតក្រុមការងារវេទិកាវិមជ្ឈការ (DFWG) ដាច់ដោយឡែកមួយដើម្បីរៀបចំ សម្រប សម្រួល និង ប្រតិបត្តិការងារនេះ។

## អំពីវេទិកា

វេទិកាវិមជ្ឈការស្វែងរកបញ្ហា និង ការប្រឈមនានាចំពោះការងារអភិបាលកិច្ចមូលដ្ឋាន។ វេទិកាផ្ដល់ឱកាសដើម្បីពិភាក្សាថា តើ ធ្វើយ៉ាងណាដើម្បី ឱ្យក្រុមប្រឹក្សាឃុំមានលទ្ធភាពកែលអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ លើកកម្ពស់ការចូលរួមក្នុងឆាកនយោបាយ និងសង្គមស៊ីវិល ពីសំណាក បុរស និង ស្ត្រី និងដើម្បីធានាថាប្រជាពលរដ្ឋនឹងបានទទួលព័តិមានគ្រប់គ្រាន់ស្ដីពីបញ្ហានានា ដែលប៉ះពាល់ ដល់ជីវភាពរស់នៅរបស់ពួកគេ ដោយរាប់បញ្ចូលទាំងការផ្ដល់សេវាផងដែរ។ ដោយសារការចូលរួមពីអ្នកពាក់ពន្ធ័ទាំងអស់ វេទិកាបាន ផ្ដល់ឱកាសដើម្បីឱ្យអ្នកចូលរួម សហការគ្នា បង្កើត នូវអនុសាសន៏ និង យុទ្ធសាស្ត្រ សំដៅដោះស្រាយបញ្ហាទាក់ទងនឹងវិមជ្ឈការ។ អនុសាសន៏ដែលបានមកពីវេទិកាអាចត្រូវ បានគេប្រើប្រាស់ ដើម្បីតស៊ូមតិសម្រាប់ធ្វើការផ្លាស់ប្ដូរ និង សម្រេចគោលបំណងនៃគោល នយោបាយថ្នាក់ជាតិ។

## គោលដៅនៃវេទិកាគឺដើម្បីៈ

*ផ្ដល់ឱកាសអោយអ្នកពាក់ពន្ធ័ចូលរួមចែករំលែកព័តិមាន, ស្វែងរក និងលើកឡើងបញ្ហានានាជុំវិញការងារវិមជ្ឈការ បង្កើនកិច្ចសហ ប្រត្តិបត្តិការ និងសម្របសម្រួលក្នុងចំណោមអ្នកពាក់ពន្ធ័នឹងវិមជ្ឈការទាំងអស់។*

វេទិកាធ្វើឡើងនៅទីក្រុងភ្នំពេញពីរដងក្នុងមួយឆ្នាំ ហើយផ្ដោតទៅលើទិដ្ឋភាពផ្សេងគ្នានៃការយល់ឃើញអំពីវិមជ្ឈការសម្រាប់ វេទិកាមួយលើកៗ។ មកដល់បច្ចុប្បន្ននេះវេទិកាបានពិភាក្សា លើភាពជាដៃគូក្នុងការងារវិមជ្ឈការ ការគ្រប់គ្រងធនធានធម្មជាតិ និងវិមជ្ឈការ និង យេនឌ័រ។ វេទិកានិមួយៗធ្វើឡើងក្នុងរយៈពេលមួយថ្ងៃ និងមានអ្នកចូលរួមប្រមាណ២០០នាក់។ អ្នកចូលរួមមកពីគ្រប់មជ្ឈដ្ឋានរួមមាន រដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការនៅមូលដ្ឋាន, ម្ចាស់ជំនួយ ផ្នែកឯកជន អ្នកយកពតិមាន និង ស្ថាប័នសិក្សានានា។ ទិសដៅនៃវេទិកាវិមជ្ឈការ គឺដើម្បីបង្កបរិយាកាសមួយដែលនាំ មកនូវការបង្កើតក្រុមការងារចូលរួមដោយអង្គការនានា ហើយបំពេញការងារដោយឯករាជ្យ និងសង្កត់ធ្ងន់លើបញ្ហាជាក់លាក់ដែល ពិតជាកើតមានក្នុងសង្គមជាក់ស្ដែង។

## អំពីក្រុមការងារ

ក្រុមការងារជួបជុំគ្នារៀងរាល់ខែ ហើយស្វាគមន៏ជានិច្ចចំពោះសមាជិកថ្មីដែលចង់ចូលរួម។ ក្រុមការងារវេទិកាវិមជ្ឈការមាន គោលដៅកំណត់ និងស្វែងរកបញ្ហាដែលកើតឡើង និងជះឥទ្ធិពលដល់ដំណើរការកំណែទម្រង់វិមជ្ឈការនៅកម្ពុជា។ សកម្មភាពនានា របស់ក្រុមការងារ វេទិកាវិមជ្ឈការដើម្បីពង្រឹងគោលដៅនៃក្រុមការងារដើម្បីភាពជាដៃគូក្នុងវិមជ្ឈការ ដោយបង្កើនការប្រាស្រ័យ ទាក់ទង និងឱកាសសម្រាប់កសាង ភាពជាដៃគូរវាងគ្រប់អ្នកពាក់ពន្ធ័នៃវិមជ្ឈការ។

**អង្គការចូលរួមមានៈ** *PLG/SEILA, UNICEF, CIDSE, GTZ, VBNK, KID, CDRI, Oxfam GB, Ockenden, Pact Cambodia and Concern.*

ស្វាគមន៏ជានិច្ចចំពោះអង្គការដែលចាប់អារម្មណ៏ចង់ចូលរួមនៅក្នុងក្រុមការងារវេទិកាវិមជ្ឈការ។ សម្រាប់ពតិមានបន្ថែមសូមទាក់ទង លោកវ៉ាន់ ថេន អង្គការផេក កម្ពុជា ទូរសព្ទ័លេខ ០២៣ ២១៧ ៨៥៥។